**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Sep-2011, 10:24
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំ ស្តីពី ការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានា**

---

**សហមេធាវីការពារក្តី:**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ដាក់ជូន ៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម **និល ណុន** ប្រធាន

ចៅក្រម **ធូ មណី**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តារ៉ា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) លោក អៀង សារី តទៅនេះ សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំ ស្តីពី ការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានា (“សំណើរបស់ ក.ស.ព”)[១]។ សារណាតបនេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយហេតុថា ក.ស.ព ធ្វើការប្រៀបធៀបទាំងមិនត្រឹមត្រូវ នូវសេចក្តីសង្កេតរបស់ អៀង សារី (“សេចក្តីសង្កេតនានា”)[២] ទៅលើការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណាតបនានារបស់មេធាវីការពារក្តី លើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទជាថ្មីឡើងវិញនៅក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“ការឆ្លើយតបរួម”)[៣] ជាមួយនឹងការឆ្លើយតបទៅនឹងការឆ្លើយតបនានា។ សេចក្តីសង្កេតទាំងនេះ មិនអាចប្រៀបធៀបជាមួយនឹងការឆ្លើយតបទៅនឹងការឆ្លើយតបបានទេ ហើយត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលយកដោយមិនចាំបាច់មានការស្នើសុំនោះឡើយ។ លើសពីនេះទៅទៀត ការទទួលយកសេចក្តីសង្កេតនានាដាក់ទៅក្នុងសំណុំរឿង គឺពិតជាការអនុវត្តជាក់ស្តែងមួយ ដែលអាចទទួលយកបាន។

## I. សារណាតប

១. សេចក្តីសង្កេតទាំងនេះមិនមែនជាការឆ្លើយតបទៅនឹងការឆ្លើយតបនោះទេ។ ដូចមានសរសេរនៅក្នុងចំណងជើងរបស់វា សេចក្តីសង្កេតទាំងនេះ គឺជាសេចក្តីសង្កេតទៅលើសេចក្តីថ្លែងជាក់លាក់

---

[១] សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំអំពីការដាក់ការឆ្លើយតប ទៅនឹងចម្លើយតបនានា ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១១ ឯកសារលេខ E112។

[២] សេចក្តីសង្កេតរបស់ អៀង សារី ទៅលើការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទជាថ្មីឡើងវិញនៅក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១ ឯកសារលេខ E95/7។

[៣] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តី លើសំណើរបស់សហព្រះរាជអាជ្ញាសុំកំណត់បទចោទជាថ្មីឡើងវិញនៅក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១១ ឯកសារលេខ E95/6។

មួយចំនួនដែលខុស សេចក្ដីថ្លែងដែលធ្វើឲ្យយល់ច្រឡំ និងការកំណត់បទចោទសាជាថ្មីដែលខុស ដែលធ្វើឡើងដោយ ក.ស.ព។ សេចក្ដីសង្កេតទាំងនេះ ត្រូវបានដាក់ជូនដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្ដីមិនបាន "បើកការជជែកតវ៉ាសាជាថ្មីម្ដងទៀតទៅលើបញ្ហានានាដែលកំពុងតែមានទំនាស់"[៤] នោះទេ និងមិនបានលើកឡើងពីចំណុចទាំងឡាយនៅក្នុងការឆ្លើយតបរួម ដែលមេធាវីការពារក្ដីមិនបានយល់ស្របនោះឡើយ។ មេធាវីការពារក្ដីបានកម្រិតសេចក្ដីសង្កេតនានារបស់ខ្លួនយ៉ាងប្រុងប្រយ័ត្ន និងយ៉ាងតឹងរ៉ឹងបំផុត ក្នុងការលើកឡើងអំពី សេចក្ដីថ្លែងដែលខុស សេចក្ដីថ្លែងដែលនាំធ្វើឲ្យយល់ច្រឡំ និងការកំណត់បទចោទដែលខុសខាងអង្គច្បាប់ និងអង្គហេតុ។

២. "សេចក្ដីសង្កេតទាំងនេះ" មិនបានយោងទៅសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្ដីណែនាំអនុវត្ត") នោះទេ។ ក.ស.ព បានដាក់ "សេចក្ដីសង្កេត"ជាច្រើនដង (និងថែមទាំងដាក់សេចក្ដីសង្កេតនានានៅក្នុងដំណើការនីតិវិធី ដែលខ្លួនមិនមែនជាភាគីថែមទៀតផង)[៥]។ សហព្រះរាជអាជ្ញាមិនដែលស្នើសុំការអនុញ្ញាតដើម្បីធ្វើដូច្នេះនោះទេ។

៣. គេមិនអាចធ្វើសេចក្ដីសន្និដ្ឋានថា សារណាមួយអាចត្រូវបានហាមឃាត់ ប្រសិនបើសារណានោះមិនបានលើកឡើងច្បាស់លាស់នៅក្នុងសេចក្ដីណែនាំអនុវត្តនោះទេ។ បើពុំនោះទេ សារណាភាគច្រើនដែលត្រូវបានទទួលយកជាទម្លាប់មកហើយនោះ ដូចជា សេចក្ដីសង្កេត សំណើសុំ និងការកត់សម្គាល់ នឹងត្រូវបានហាមឃាត់ហើយ ព្រោះថា សារណាទាំងនេះមិនត្រូវបានសម្អាងនៅក្នុងសេចក្ដីណែនាំអនុវត្តទេ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់អំពីសេចក្ដីណែនាំអនុវត្តពាក់ព័ន្ធនឹងការឆ្លើយតបនានា នៅក្នុងសេចក្ដីណែនាំរបស់ខ្លួនទាក់ទងនឹងសារណាតប ការឆ្លើយតបទៅនឹងសារណាតប និងការដាក់ឯកសារតែមួយភាសានៅក្នុងករណីពិសេស ("សេចក្ដី

---

[៤] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្ដី លើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទជាថ្មីឡើងវិញនៅក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពី បទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១១ ឯកសារលេខ E95/6។

[៥] *សូមមើល* សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា លើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីស្ដីពីការព្រមានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១០ ឯកសារលេខ D367/1/2។ នៅក្នុងកថាខណ្ឌ ១ ក.ស.ព លើកឡើងថា "សហព្រះរាជអាជ្ញា មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីទាក់ទិននឹងកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្ដីនោះទេ"។

ណែនាំ")[៦] សេចក្តីណែនាំមិនបាននិយាយអំពីការដាក់សេចក្តីសង្កេតទាំងឡាយនោះទេ។

៤. ការដាក់សំណើសុំការអនុញ្ញាត ដើម្បីឆ្លើយតបរួមគ្នានៅក្នុងសារណាតប ដូចដែលមេធាវីការពារក្តីបានធ្វើឡើងនៅក្នុងស្ថានភាពដទៃទៀតនោះ[៧] គឺមិនមែនជានីតិវិធីដែលមិនត្រឹមត្រូវនោះទេ ហើយការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងដាក់ការឆ្លើយតបនេះទៅក្នុងសំណុំរឿង ក៏មិនខុសនោះដែរ។ ការដាក់សំណើសុំការអនុញ្ញាត ដើម្បីឆ្លើយតបរួមគ្នានៅក្នុងសារណាតបមួយ គឺជួយដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើការពិចារណាថាតើគួរផ្តល់ការអនុញ្ញាតដែរឬយ៉ាង និងជួយពន្លឿនដំណើរការនីតិវិធីផង។ វាជាការខាតបង់ពេលវេលាក្នុងការដាក់សំណើសុំការអនុញ្ញាត រួចហើយរង់ចាំសេចក្តីសម្រេច និងក្រោយមកទើបដាក់សារណាតប។ វាជាការឆាប់រហ័សបំផុតសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលបានសារណាទាំងពីរនៅចំពោះមុខខ្លួន ក្នុងពេលតែមួយ និងបន្ទាប់មកទើបសម្រេចថាតើអង្គជំនុំជម្រះសាលាដំបូង នឹងទទួលយកសារណាតបនេះដែរឬអត់នោះ។ ឯកសារ<u>ទាំងអស់</u>ដែលបានដាក់ជូន គួរត្រូវបានដាក់ទៅក្នុងសំណុំរឿង ដោយហេតុថា វាបង្កើតបានជាកំណត់ត្រានៃដំណើរការនីតិវិធី។ ការដាក់ទៅក្នុងសំណុំរឿង គឺមិនដូចគ្នាទៅនឹងការទទួលយកនោះទេ។ លើសពីនេះទៅទៀត ការដាក់ទៅក្នុងសំណុំរឿង គឺវាមិនធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃការស្នើសុំការអនុញ្ញាតនោះទេ។ អង្គជំនុំជម្រះសាលាដំបូងនៅតែរក្សាឆន្ទានុសិទ្ធិ ដើម្បីពិចារណាថាតើការស្នើសុំនេះ គួរត្រូវបានអនុញ្ញាតដែរឬអត់នោះ។

៥. អង្គជំនុំជម្រះសាលាដំបូងមានតួនាទីបញ្ជាក់ថាតើការបកស្រាយលើអង្គច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធនឹងបញ្ហាវិវាទនេះ ត្រឹមត្រូវដែរឬទេ។ ក្រុមមេធាវីការពារក្តីបានដាក់សេចក្តីសង្កេតដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការបំពេញតួនាទីនេះ។ ប្រសិនបើក្រុមមេធាវីការពារក្តី

---

[៦] សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង សារណារប ការឆ្លើយតបទៅនឹងសារណារប និងការដាក់ឯកសារតែមួយភាសានៅក្នុងករណីពិសេស ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១១ D64។

[៧] សំណើរបស់លោក អៀង សារី សុំអនុញ្ញាតឆ្លើយតប ឬសុំឱ្យមានសវនាការផ្ទាល់មាត់ និងការឆ្លើយតបទៅនឹងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១១ ឯកសារលេខ E99/1/1។

បែរជាជ្រើសរើសដាក់សំណើសុំការអនុញ្ញាតដាក់ការឆ្លើយតបវិញនោះ នោះសេចក្តីថ្លែងដែលខុស សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ និងការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គច្បាប់ របស់ ក.ស.ព នឹងប្រាកដជាផ្តល់មូលដ្ឋានគ្រប់គ្រាន់ដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់ការ អនុញ្ញាតឱ្យការដាក់ការឆ្លើយតបជាក់ជាមិនខាន ជាពិសេស ពីព្រោះតែវាហាក់ដូចជាបង្ហាញឱ្យ ឃើញថា វានឹងមិនមានសវនាការដេញដោលលើបញ្ហាទាំងនេះឡើយ ហេតុដូច្នេះហើយ វាគ្មាន ឱកាសណាផ្សេងអាចឱ្យភាគីអាចកែតម្រូវកំណត់ហេតុនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៦. ទោះបីជាការខកខានមិនផ្តល់បរិបទចំពោះការអះអាង ជាធម្មតា មិនអាចបង្កើតជាសេចក្តីថ្លែង ដែលខុស សេចក្តីថ្លែងដែលធ្វើឱ្យយល់ច្រឡំ ឬ ការកំណត់បទចោទដែលខុសខាងអង្គហេតុ និងអង្គ ច្បាប់ក៏ដោយ ក៏មានករណីផ្សេងៗទៀត ដែល ក.ស.ព អាចលើកឡើងជំហររបស់ភាគីដទៃដោយ មិនត្រឹមត្រូវ ដោយសារមិនបានផ្តល់បរិបទឱ្យបានសមស្រប។ ក.ស.ព បានធ្វើដូច្នេះក្នុងករណី មួយចំនួនមកហើយនៅក្នុងការឆ្លើយតបរួមរបស់ខ្លួន។ ឧទាហរណ៍ ក.ស.ព បានអះអាងថា ក្រុម មេធាវីការពារក្តីបានតវ៉ាថា ការរំលោភសេពសន្ថវៈគឺជាអំពើខុសច្បាប់ ក៏ប៉ុន្តែ គ្រាន់តែជា "ការឱ្យ រង្វាន់ដែលចាំបាច់សម្រាប់អ្នកធ្វើសង្គ្រាមប៉ុណ្ណោះ"[៨]។ ប្រសិនបើសេចក្តីថ្លែងនេះមិនត្រឹមត្រូវទេ នោះ អង្គជំនុំជម្រះសាលាដំបូង ភាគីដទៃៗទៀត និងសាធារណៈទូទៅ ប្រាកដជាអាចជឿជាក់ថា ក្រុមមេធាវីការពារក្តីបានលើកឡើងចំណុចមិនអាចទទួលយកបាន ខណៈខ្លួនមិនបានលើកឡើងផង នោះ។

៧. ក.ស.ព មានភារកិច្ចបង្ហាញតែការពិត ដោយមិនត្រូវធ្វើឱ្យអង្គជំនុំជម្រះយល់ច្រឡំឡើយ។ ដូច សាស្ត្រាចារ្យ Daniel Markovits នៅសាកលវិទ្យាល័យយ៉េលបានលើកឡើង ការយកចិត្តទុកដាក់ លើវិជ្ជាជីវៈដ៏ពិសេសរបស់រដ្ឋអាជ្ញា អាចយល់បាន "ដូចបានឆ្លុះបញ្ចាំងតាមរយៈអង្គហេតុដែលថា រដ្ឋអាជ្ញាជាមន្ត្រីតំណាងឱ្យរដ្ឋមួយផ្នែក នៅចំពោះមុខតតីយជន ជាជាងតំណាងឱ្យកូនក្តីធម្មតានៅ ចំពោះមុខសាលាក្តីអព្យាក្រឹតមួយ។ យ៉ាងហោចណាស់ តាមគោលការណ៍ រដ្ឋពុំមានផល ប្រយោជន៍អ្វីចង់យកឈ្នះដើម្បីខ្លួនឯងនោះឡើយ ពីព្រោះថារដ្ឋមិនគួរស្វែងរកភាពអយុត្តិធម៌ ឡើយ។ រដ្ឋពុំចាំបាច់ការពារខ្លួនឯងពីអាជ្ញាធរ ដោយហេតុថាខ្លួនជាអាជ្ញាធរស្រាប់ទៅហើយ។ ហេតុដូច្នេះ ការយកចិត្តទុកដាក់ដ៏ពិសេសរបស់រដ្ឋអាជ្ញាលើតែការពិត និងភាពយុត្តិធម៌ ពង្រីកនូវ

---

[៨] ចម្លើយតបរួម កថាខណ្ឌ ៧២។

តួនាទីមួយ ដែលរចនាសម្ព័ន្ធដើមរបស់វា ដាកចេញពីរចនាសម្ព័ន្ធនៃការតស៊ូមតិប្រឆាំងនឹងគូបដិបក្ខ”[៥]។

៨. ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យច្រានចោលសំណើរបស់ ក.ស.ព។ សេចក្តីបង្គាប់អំពីការដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនានា គឺមិនចាំបាច់ឡើយ ដោយហេតុថា សេចក្តីបង្គាប់អំពីការដាក់ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយសមរម្យទៅលើស្ថានភាព ដែលបានកើតឡើង រួចទៅហើយ ក្នុងករណីភាគីមួយចង់ដាក់ការឆ្លើយតបទៅនឹងការឆ្លើយតប ក៏ប៉ុន្តែ ស្ថានភាពបែបនោះពុំដែលធ្លាប់បានកើតឡើងឡើយ។ ក្រុមមេធាវីការពារក្តីបានដាក់សេក្តីសង្កេត ដោយពុំដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបឡើយ។ អង្គជំនុំជម្រះសាលាដំបូងគួរច្រានចោលសំណើនេះ ដែលស្នើសុំឲ្យបញ្ជាក់ថា ការអនុញ្ញាតសុំដាក់ការឆ្លើយតប ត្រូវដាក់មុនពេល និងដោយឡែកពីការឆ្លើយតបទៅនឹងការឆ្លើយតប ដោយសារតែការធ្វើដូច្នេះ នឹងបណ្តាលឲ្យមានការពន្យារពេលវេលាដោយពុំចាំបាច់។ អង្គជំនុំជម្រះសាលាដំបូងក៏គួរច្រានចោលសំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ដល់ក្រឡាបញ្ជី កុំឲ្យដាក់ការឆ្លើយតបទៅនឹងការឆ្លើយតបនៅក្នុងសំណុំរឿងផងដែរ រហូតទាល់តែការអនុញ្ញាតសុំដាក់ការឆ្លើយតបទៅនឹងការឆ្លើយតប ត្រូវបានយល់ព្រមជាមុនសិន ពីព្រោះតែការដាក់ចូលទៅក្នុងសំណុំរឿងគឺមានលក្ខណៈខុសពីការទទួលយកការឆ្លើយតបទៅនឹងការឆ្លើយតប។ រាល់សារណាទាំងអស់ដែលបានដាក់ហើយនោះគួរដាក់ចូលទៅក្នុងសំណុំរឿង ដើម្បីធ្វើជាកំណត់ហេតុថា សារណាទាំងអស់នោះបានដាក់រួចរាល់អស់ហើយ។ អង្គជំនុំជម្រះសាលាដំបូងនៅតែមានឆន្ទានុសិទ្ធិនៅក្នុងការសម្រេចថាតើខ្លួនយល់ឃើញថា សារណាទាំងអស់នោះទទួលយកបាន ឬក៏មិនបាន និងសម្រេចថាតើខ្លួននឹងទទួលយកអង្គសេចក្តីនៃទឡ្ហីករណ៍នៅក្នុងសារណាទាំងនោះដែរឬយ៉ាងណា។

## II. សំណូមពរ

[៥] Daniel Markovits A Modern Legal Ethics: Adversary Advocacy in a Democratic Age 87 (Princeton University Press 2008)។

**អាស្រ័យហេតុនេះ** យោងទៅលើសំអាងហេតុទាំងអស់ដូចបានលើកឡើងនៅក្នុងសារណានេះ ក្រុមមេធាវីការពារក្តី សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ច្រានចោលសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំសេចក្តីណែនាំអំពីការដាក់ការឆ្លើយតប ទៅនឹងការឆ្លើយតបនានា។

សូមចៅក្រុមអង្គជំនុំជម្រះសាលាដំបូងទទួលយកសារណានេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៦** ខែ **កញ្ញា** ឆ្នាំ **២០១១**

សហមេធាវីការពារក្តីរបស់លោក **អៀង សារី**

**អាង ឧត្តម** | **Michael G. KARNAVAS**